# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យភ្ជុំនៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩
# កុំរស់ឬស្លាប់សម្រាប់ខ្លួនឯង

**អត្ថបទទី១៖ វិវរណៈ ៧,២-៤.៩-១៤**

គេនាំគ្នាបន្លឺសំឡេងឡើងយ៉ាងខ្លាំងៗថា៖ «មានតែព្រះនៃយើងដែលគង់នៅលើបល្ល័ង្ក និង កូនចៀមប៉ុណ្ណោះទេ ដែលសង្គ្រោះយើង»។ វវ ៧,១០

**អត្ថបទទី២៖ ហេប្រឺ ៤,១២-១៣**

គ្មានសត្វលោកណាមួយដែលព្រះបន្ទូលមើលមិនឃើញឡើយ ចំពោះព្រះនេត្ររបស់ព្រះអង្គ អ្វីៗទាំងអស់នៅទទេ ឥតបិទបាំងទាល់តែសោះ។ យើងត្រូវទូលរៀបរាប់ថ្វាយព្រះបន្ទូលពី គ្រប់កិច្ចការទាំងអស់។ ហប ៤,១៣

**ដំណឹងល្អ៖ ម៉ាកុស ១០,១៧-៣០**

ព្រះយេស៊ូទតមើលទៅគាត់ ហើយមានព្រះហឫទ័យស្រឡាញ់គាត់ ទ្រង់មានព្រះបន្ទូលថា៖ « នៅខ្វះកិច្ចការមួយទៀតដែលអ្នកមិនទាន់ធ្វើ គឺត្រូវអញ្ជើញទៅលក់អ្វីៗដែលអ្នកមាន រួចចែក ឲ្យជនក្រីក្រទៅ ធ្វើដូច្នេះ ទើបអ្នកមានសម្បត្តិសួគ៌ បន្ទាប់មក សឹមអញ្ជើញមកតាមខ្ញុំ»។ មក ១០,២១

បងប្អូនជាទីស្រឡាញ់!

ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ព្រះជាម្ចាស់ បានចងសម្ពន្ធមេត្រីរវាងយើងនឹងព្រះអង្គដើម្បីសង្គ្រោះយើង។ ពីដើមរៀងមករហូតដល់អវសាន នៃពិភពលោក ព្រះជាម្ចាស់ស្ថិតស្ថេរដដែល ប៉ុន្តែយើងដែលជាមនុស្សធម្មតាយើងកើត យើង ចាស់ និងយើងស្លាប់។ ជីវិតរបស់យើងប្រែប្រួលយ៉ាងខ្លាំង ទាំងការរស់នៅ ទាំងម្ហូបអាហារ ទាំង ការសិក្សា... ថ្មីៗនេះអ្នកដឹកនាំពិភពលោកបានជួបជុំគ្នាពិភាក្សាអំពីប្រធានបទ “**បម្រែបម្រួល អាកាសធាតុ**” គេបានប្រកាសថាឥឡូវនេះដល់ពេលវេលាសង្គ្រោះផែនដីរបស់យើង។ អាកាស ធាតុប្រែប្រួល ណែនាំឲ្យយើងព្រួយបារម្ភអំពីផែនដីនិងធម្មជាតិរបស់យើង។

**តើយើងធ្វើដូចម្តេចដើម្បីសង្គ្រោះមនុស្សយើង?** ក្នុងអត្ថបទលោកអេសាយបាននិយាយថា “**ព្រះជាម្ចាស់ជាព្រះនៃយើង យើងបានផ្ញើជីវិតលើព្រះអង្គហើយព្រះអង្គសង្គ្រោះយើង យើងបាន ផ្ញើជីវិតលើព្រះអម្ចាស់មែនចូរយើងសប្បាយរីករាយនិងមានអំណរឡើង ត្បិតព្រះអង្គសង្គ្រោះ យើង**”។ យើងដូចជាបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមរយៈព្យាការីអេសាយ សម្រាប់ ជីវិតរបស់យើងថ្ងៃនេះ យើងបានផ្ញើជីវិតទៅលើព្រះជាម្ចាស់ហេតុនេះហើយព្រះជាម្ចាស់សង្គ្រោះ យើង។ ដួងចិត្តរបស់យើង វិញ្ញាណរបស់យើង ចិត្តគំនិតរបស់យើងជាមនុស្សប្រែប្រួលរបៀប

ណា? មានសង្គ្រាមច្រើននៅលើពិភពលោកសព្វថ្ងៃ ដែលបានធ្វើឲ្យមនុស្សជាច្រើននាក់បានស្លាប់ យើងមានសង្គ្រាមសេដ្ឋកិច្ច យើងមានសង្គ្រាមសាសនា ដែលបានណែនាំឲ្យមនុស្សយើងពិបាកចិត្ត។ សង្គ្រាមបានធ្វើឲ្យមនុស្សជាច្រើន ភៀសខ្លួនចេញពីប្រទេសកំណើតរបស់ខ្លួនដោយសារគ្មានម្ហូបអាហារគ្រប់គ្រាន់ គ្មានសេចក្ដីសុខសាន្ត គ្មានសុវត្ថភាពក្នុងការរស់នៅ។ សម្ដេចប៉ាប បានណែនាំឲ្យព្រះសហគមន៍អធិដ្ឋានសម្រាប់ជនភៀសខ្លួនទូទាំងពិភពលោក នៅក្នុងសម្ពន្ធមេត្រីចាស់ជនជាតិអ៊ីស្រាអែលបានគេចពីជនជាតិហេប្រឺ នៅពេលនោះមានលោកម៉ូសេដែលណែនាំពួកគេដើរនៅក្នុងវាលរហោស្ថានដើម្បីទៅដល់ដីដ៏វិសុទ្ធ ដែលព្រះជាម្ចាស់បានរៀបចំ។ តែសព្វថ្ងៃ យើងមានលោកម៉ូសេ មកពីណាដើម្បីដឹកនាំជនភៀសខ្លួនដើម្បីទៅរកជីវិតថ្មី។

យើងមានប្រជាជនជាង១លាននាក់ ដែលបានចេញពីប្រទេសយើងទៅធ្វើការនៅប្រទេសនានា យើងអាចសួរខ្លួនឯងថា **តើបេះដូងរបស់យើង ដួងចិត្តរបស់យើង ផ្លូវវិញ្ញាណរបស់យើងបានប្រែប្រួលដូចម្ដេច?** យើងមិនតែសង្គ្រោះផែនដី គឺយើងត្រូវសង្គ្រោះមនុស្សដែរ ប្រសិនបើមនុស្សទទួលបានការសង្គ្រោះគឺមនុស្សយើងដែលអាចសង្គ្រោះផែនដីបាន។ មនុស្សដែលពោរពេញដោយសេចក្ដីសុខ នៅក្នុងដួងចិត្តផ្ទាល់ នៅក្នុងក្រុមគ្រួសារផ្ទាល់អាចរស់នៅយ៉ាងសុខដមរមនារួមជាមួយផែនដី រួមជាមួយបរិស្ថាន រួមជាមួយបងប្អូនឯទៀតៗ។ ព្រះជាម្ចាស់បានប្រទានផែនដីទាំងមូលឲ្យយើងត្រួតត្រា ព្រះជាម្ចាស់បានប្រទានមនុស្សលោកដើម្បីឲ្យយើងថែរក្សា និងបង្កើតទំនាក់ទំនងរវាងគ្នានិងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសេចក្ដីស្រឡាញ់។ **តើយើងបានធ្វើអ្វីនឹងទ្រព្យសម្បត្តិ ដែលព្រះជាម្ចាស់បានដាក់នៅក្នុងរូបកាយរបស់យើង?** ប្រសិនបើយើងមានពន្លឺរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ទំនាក់ទំនងដែលយើងមានជាមួយបងប្អូនឯទៀតៗ ជាមួយផែនដី ជាមួយសេដ្ឋកិច្ច ជាមួយសង្គមទាំងមូលអាចប្រែប្រួលអស់ហើយ។ ព្រះជាម្ចាស់មានព្រះបន្ទូលថា "**សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**" បើយើងរស់នៅក្នុងធម្មវិន័យរបស់ព្រះអង្គពិតមែន សង្គមរបស់យើង ពិភពលោករបស់យើងនិងប្រែប្រួលនៅក្នុងរបៀបអស្ចារ្យ។

ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺ "**អ្នកណាដាក់ចិត្តជាអ្នកក្រីក្រ អ្នកណាកសាងសុខសន្តិភាព អ្នកណាមានចិត្តមេត្តាករុណា អ្នកណាដែលស្រេកឃ្លានយុត្តិធម៌ អ្នកនោះមានសុភមង្គលហើយ**"។ អាស្រ័យលើយើង ដែលយកចិត្តទុកដាក់និងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីកែប្រែចិត្តគំនិតឬអត់។ នៅក្នុងអត្ថបទទីពីរ "**គ្មាននរណាម្នាក់រស់ឬស្លាប់សម្រាប់ខ្លួនឯងឡើយ ត្បិតបើយើងរស់យើងរស់និងយើងស្លាប់សម្រាប់ព្រះអម្ចាស់**" ប៉ុន្តែសព្វថ្ងៃមនុស្សយ៉ាងច្រើនរស់នៅនិងស្លាប់សម្រាប់តែខ្លួនឯង។ ព្រះជាម្ចាស់ បានណែនាំឲ្យយើងរស់នៅនិងស្លាប់សម្រាប់ព្រះជាម្ចាស់ នេះ

ជាអ្វីដែលណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី និងអាចជួយកែប្រែពិភពលោក។ ដើម្បីបង្កើតពិភពលោកថ្មី ឲ្យយើងទៅជាអ្នកបម្រើដែលត្រៀមខ្លួនទន្ទឹងរង់ចាំព្រះជាម្ចាស់ ដែលសុខចិត្តបម្រើបងប្អូនឯទៀតៗ ដែលសុខចិត្តបម្រើផែនដីដែលជាផ្ទះរបស់យើង។ ព្រះជាម្ចាស់ចង់សង្គ្រោះយើង សម្រាប់ថ្ងៃនេះសម្រាប់ថ្ងៃស្អែក ហេតុនេះហើយឲ្យយើងបើកចិត្តគំនិតរបស់យើងដើម្បីទទួលការសង្គ្រោះពីព្រះជាម្ចាស់។ សង្គមរបស់យើង ប្រទេសរបស់យើង ពិភពលោករបស់យើងអាចរកឃើញសេចក្តីសុខមកពីព្រះជាម្ចាស់ ដែលមានតែសេចក្តីសុខនេះធ្វើឲ្យសង្គមនិងពិភពលោកអាចប្រែប្រួលនៅក្នុងរបៀបត្រឹមត្រូវ។ គ្រួសាររបស់លូវីស និងហ្សេលី ដែលបានយកចិត្តទុកដាក់កសាងគ្រួសារដ៏សុខសាន្ត ដោយបានទីពឹងទាំងស្រុងលើព្រះជាម្ចាស់ បានផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ នៅក្នុងជីវិតធម្មតាប្រចាំថ្ងៃដោយដឹងថាព្រះជាម្ចាស់មានវត្តមាន ព្រះជាម្ចាស់ជាសមាជិកនៅក្នុងក្រុមគ្រួសារគេ។ ដូច្នេះ ណែនាំឲ្យគ្រួសាររកឃើញសេចក្តីសុខ ទោះបីមានទុក្ខលំបាក ទោះបីមានជំងឺ ទោះបីមានអ្នកស្លាប់នៅក្នុងក្រុមគ្រួសារ ប៉ុន្តែគេរកឃើញសេចក្តីសុខ។

ដួងចិត្តរបស់យើង បេះដូងរបស់យើង វិញ្ញាណរបស់យើង ស្រេកឃ្លានសេចក្តីសុខសាន្ត ហេតុនេះហើយឲ្យយើងបើកចិត្តគំនិតទៅលើព្រះជាម្ចាស់។ ជីវិតរបស់យើងខ្លីណាស់ ថ្ងៃណាមួយព្រះអម្ចាស់នឹងយាងមក ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃឲ្យយើងយកចិត្តទុកដាក់ទៅជាអ្នកបម្រើដែលមានចិត្តស្មោះត្រង់ ដែលមានចិត្តបម្រើបងប្អូនឯទៀតៗ ដើម្បីបម្រើព្រះជាម្ចាស់ ដើម្បីបម្រើផែនដីរបស់យើង។ គម្រោងការរបស់ព្រះជាម្ចាស់ មិនមែនជាសុបិនមួយដែលមិនអាចកើតឡើង គម្រោងការព្រះជាម្ចាស់អាចកើតឡើងបានលុះត្រាតែ យើងយកចិត្តទុកដាក់ដើម្បីកសាងពិភពថ្មី ដោយចិត្តមនុស្សដែលចេះស្រឡាញ់អ្នកដទៃ មានភ្នែក បេះដូង គំនិត ដូចព្រះជាម្ចាស់ផ្ទាល់។ ពិតមែន សេចក្តីស្រឡាញ់មិនរកឃើញប្រភពនៅក្នុងដួងចិត្តរបស់យើងផ្ទាល់ សេចក្តីស្រឡាញ់រកឃើញប្រភពនៅក្នុងព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ មានតែព្រះជាម្ចាស់ ដែលអាចណែនាំឲ្យពិភពរបស់យើងរកឃើញដង្ហើមថ្មីនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទៅមុខតទៅទៀត។ ព្រះជាម្ចាស់បានបង្កើតយើង ព្រះជាម្ចាស់បានផ្ញើផែនដីឲ្យយើងថែរក្សា ព្រះជាម្ចាស់បានណែនាំឲ្យយើងថែរក្សាមនុស្សទាំងអស់ ព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់ចង់សង្គ្រោះយើង។ ហេតុនេះហើយ នៅថ្ងៃដែលយើងគោរពវិញ្ញាណក្ខន្ធរបស់បងប្អូនឯទៀតៗ ឲ្យយើងបើកចិត្តគំនិតដើម្បីណែនាំឲ្យព្រះអង្គសង្គ្រោះយើង ពេលយើងទទួលការសង្គ្រោះពីព្រះអង្គយើងមានសមត្ថភាពសង្គ្រោះពិភពលោក។ អាម៉ែន៕